នស/រកត/០៤០៥/១៩៣

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/ ០៩ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិសម្រាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការការពារបូរណភាពទឹកដីឱ្យបានស្ថិតស្ថេរគង់វង្ស ស្របតាមមាត្រា២នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ :** ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-តំណាងព្រះមហាក្សត្រ | ១រូប | ជាប្រធាន |
| ២-តំណាងប្រធានព្រឹទ្ធសភា | ១រូប | ជាអនុប្រធាន |
| ៣-តំណាងប្រធានរដ្ឋសភា | ១រូប | ជាអនុប្រធាន |
| ៤-តំណាងប្រមុខរាជរដ្ឋាភិបាល | ១រូប | ជាសមាជិក |
| ៥-តំណាងគណបក្សប្រជាជនកម្ពុជា | ១រូប | ជាសមាជិក |
| ៦-តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច | ១រូប | ជាសមាជិក |
| ៧-តំណាងគណបក្សសមរង្ស៊ី | ១រូប | ជាសមាជិក |

**មាត្រា ៣** : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែនមានភារកិច្ច ៖

-ស្រាវជ្រាវ និងសិក្សាពីបញ្ហាព្រំដែនគោក និងព្រំដែនសមុទ្រ រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង

-ជូនយោបល់ដល់រាជរដ្ឋាភិបាល ក្នុងការកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ ស្តីពីការកំណត់ព្រំដែនដីគោក និងព្រំដែនសមុទ្រ ក៏ដូចជាការអនុវត្តគោលនយោបាយការពារបូរណភាពទឹកដី របស់រាជរដ្ឋាភិបាល និងតាមដានការវិវត្តទូទៅនៃដំណោះស្រាយព្រំដែន ដែលទទួលបានក្នុងការចរចា ក៏ដូចជាការអនុវត្តលើដីជាក់ស្តែង រវាងព្រះរាជាណាចក្រកម្ពុជាជាមួយបណ្តាប្រទេសជិតខាង

-ចុះពិនិត្យលើដីជាក់ស្តែងនូវបាតុភាព ដែលកើតមានឡើងនៅតាមបណ្តោយព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង

-ធ្វើរបាយការណ៍តាមកំណត់កាលនីមួយៗ ថ្វាយព្រះមហាក្សត្រ អំពីសកម្មភាពនៃការដោះស្រាយបញ្ហាព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង។

**មាត្រា ៤** :ការប្រជុំនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ត្រូវកោះប្រជុំដោយប្រធាន ឬតាមសំណើចំនួន១ភាគបីយ៉ាងតិចនៃសមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន។

**មាត្រា ៥** :ការប្រជុំ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ត្រូវយកតាមការឯកភាពគ្នាមតិនៃសមាជិកវត្តមានទាំងអស់ ។ សមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ។

**មាត្រា ៦** :គណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែននៃរាជរដ្ឋាភិបាល ជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ៧**: រាល់ការចំណាយសម្រាប់ដំណើរការរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៨**: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៩**: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហមុនី

នស.រកត.០៥០៤.២១៦

**ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃ ទី ២៧ ខែ មេសា ឆ្នាំ ២០០៥**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ:០១២/០៥ រ.ចច
រាជធានីភ្នំពេញ .ថ្ងៃទី២៧ខែមេសាឆ្នាំ២០០៥
សម្តេចចៅហ្វាវាំង វររាជវាំងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ ... ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់